00646263

E9/4/7

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ** / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការជូនដំណឹងរបស់លោក អៀង សារី ពាក់ព័ន្ធនឹងការដាក់ការជំទាស់ទៅលើសាក្សីដែលបាន ស្នើដោយ កសព (ឧបសម្ព័ន្ធ ៣, ៣(ក) និង ៥)**

---

__ដាក់ដោយ៖__

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

__ផ្ញើជូន៖__

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

__ផ្ញើជូន៖__

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 21 / 02 / 2011
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះ សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា គាត់សូមរក្សាសិទ្ធិដើម្បីជំទាស់ទៅលើសាក្សីទាំងឡាយដែលបានស្នើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា មានរាយឈ្មោះក្នុងបញ្ជី**ឧបសម្ព័ន្ធ ៣** (សាក្សី-ដែលមិនមានបានស្នើសុំវិធានការការពារ), ក្នុងបញ្ជី**ឧបសម្ព័ន្ធ ៣ក** (សាក្សីដែលបានស្នើសុំវិធានការការពារ) និង ក្នុងបញ្ជី**ឧបសម្ព័ន្ធ ៥** (សាក្សីត្រូវបញ្ជាក់យថាភូតលើឯកសារដែល កសព មិនស្នើសុំអោយកោះហៅនាពេលនេះ)[1]។ ការដាក់ឯកសារដោយឡែកទាក់ទងនឹងសាក្សីដែលបានរាយឈ្មោះនៅក្នុង **ឧបសម្ព័ន្ធ ២** (អ្នកជំនាញ) និង **ឧបសម្ព័ន្ធ ៤** (ដើមបណ្តឹងរដ្ឋប្បវេណី) នឹងដាក់ជូនតាមក្រោយ។ មានសាក្សីចំនួន ២៤៦នាក់ ត្រូវបានរាយឈ្មោះក្នុង **ឧបសម្ព័ន្ធ ៣** ហើយសេចក្តីសង្ខេបនៃការធ្វើសក្ខីកម្មរបស់សាក្សីដែលនឹងបានស្នើឡើងទាំងនេះមិនទាន់ត្រូវបានផ្តល់អោយដោយ កសព នៅឡើយទេ។ ហេតុដូច្នេះវាមិនអាចធ្វើទៅបានទេនៅពេល ដើម្បីសម្រេចថាតើការជំទាស់ប្រឆាំងនឹងសាក្សីដែលបានស្នើឡើងទាំងនេះមានការចាំបាច់ដែរឬអត់ឡើយ[2]។ មេធាវីការពារក្តី មិនទាន់ត្រូវគេបានផ្តល់អោយនូវ**ឧបសម្ព័ន្ធ ៣ក** ហេតុដូច្នេះវាមិនអាចធ្វើទៅបានទេនៅពេល ដើម្បីសម្រេចថាតើការជំទាស់ប្រឆាំងនឹងសាក្សីដែលបានស្នើឡើងទាំងនេះមានការចាំបាច់ដែរឬអត់ឡើយ ។ កសព បានថ្លែងថា ខ្លួនមិនមានបំណងនឹងស្នើសុំអោយកោះហៅសាក្សីទាំងឡាយដែលបានស្នើក្នុង **ឧបសម្ព័ន្ធ ៥** នាពេលនេះទេ។ ហេតុដូច្នេះ មិនមានការជំទាស់ដែលយល់ឃើញថាចាំបាច់ទៅនឹងសាក្សីទាំងឡាយដែលបានស្នើក្នុង **ឧបសម្ព័ន្ធ ៥** នាពេលនេះទេ។ បើសិនជា កសព ប្រកាសនៅដំណាក់កាលក្រោយថា ខ្លួនមានបំណងហៅសាក្សីទាំងឡាយដែលបានស្នើសុំទាំងនេះ មេធាវីការពារក្តីសូមរក្សាសិទ្ធិជំទាស់នៅក្នុងពេលវេលាសមរម្យមួយ នៅពេលបានទទួលសេចក្តីសង្ខេបនៃសក្ខីកម្មរបស់សាក្សីដែលនឹងបានស្នើឡើងទាំងនេះ និងសេចក្តីសង្ខេបនៃកោសល្យវិច្ច័យរបស់អ្នកទាំងនេះបើសិនជាមាន។ បើសិនជាសេចក្តីថ្លែងការណ៍ទាំងឡាយដែលធ្វើឡើងដោយសាក្សីដែលបានស្នើឡើងទាំងនេះ នឹងត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[3] មេធាវីការពារក្តីរក្សាសិទ្ធិប្រឈមមុខតទល់នឹងសាក្សីទាំងនេះ។

---

[1] *ករណីលោក* នួន ជា, សំណុំរឿង ០០២-១៩-០៩-២០០៧-អវតក/អជសដ, បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញារួមទាំងឧបសម្ព័ន្ធសម្គាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥, ឧបសម្ព័ន្ធ E9/4.3, E9/4.5។

[2] មានករណីលើកលែងមួយ ពោលគឺ លោកស្រី Ewa Tabeau ដែលត្រូវបានគេស្នើឡើងក្នុងឧបសម្ព័ន្ធ ៣ ។ វាទំនងជាថា កសព គួរស្នើផ្សេងពីនេះដោយស្នើសុំលោកស្រីធ្វើជាអ្នកជំនាញក្នុងឧបសម្ព័ន្ធ ២។ ការជំទាស់នឹងលោកស្រី Tabeau នឹងដាក់ដោយឡែក។

[3] នាដំណាក់កាលនេះ មេធាវីការពារក្តីមិនដឹងថា តើ កសព នឹងស្នើសុំដាក់បញ្ចូលចម្លើយទាំងឡាយរបស់សាក្សីដែលបានស្នើសុំដែរឬទេ។ អង្គជំនុំជម្រះសាលាដំបូងមិនបានតម្រូវអោយភាគីនានាអោយដាក់នូវព័ត៌មានទាំងនេះឥឡូវនេះទេ លុះត្រាតែដល់

E9/4/7

សូមលោកចៅក្រមអង្គជំនុំសាលាដំបូងទទួលសេចក្ដីជូនដំណឹងនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

ថ្ងៃទី ១៣ មេសា ២០១១ បើយោងតាមដីកាបង្គាប់របស់ អង្គជំនុំជម្រះសាលាដំបូង។ *ករណីលោក* នួន ជា, សំណុំរឿង 00២-១៩-0៩-២00៧-អវតក/អជសដ, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ មករា ២០១១ ឯកសារលេខ E9, ERN: 00635754-00635759 កថាខណ្ឌ ១២-១៤។